# ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០១៧

**កំណើនផ.ស.ស និងការចូលរួមចំណែកដល់កំណើនតាមវិស័យនីមួយៗ**




ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០១៧

ទោះបីសេដ្ឋកិច្ចពិភពលោកកំពុងស្ថិតក្នុងភាពមិនប្រាកដប្រជាជាច្រើន ដែលរួមមានទាំងហានិភ័យ និងបញ្ហាប្រឈម ទាំងក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ សេដ្ឋកិច្ចកម្ពុជានៅតែអាចបន្តកំណើនខ្ពស់ និងរឹងមាំក្នុងរយៈពេលខ្លី និងមធ្យមខាងមុខនេះ។ ជាមួយនឹងសមិទ្ធផលនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានចាត់ទុកប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅតំបន់អាស៊ី ហើយបានប្រសិទ្ធនាមប្រទេសកម្ពុជា ជា "**ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី**" ទៀតផង។

ក្នុងឆ្នាំ ២០១៦ កន្លងទៅ កម្ពុជារក្សាបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៧,០% ដោយសារការងើបឡើងវិញនៃកំណើនក្នុងវិស័យកសិកម្ម បន្ទាប់ពីស្ទើរតែគ្មានកំណើនសោះក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ខណៈដែលកំណើនវិស័យឧស្សាហកម្ម និងសេវាកម្មមានភាពថមថយបន្តិច។ ការថមថយនៃកំណើនក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មនេះ បានបង្ហាញពីភាពចាំបាច់ និងបន្ទាន់នៃការអនុវត្តវិធានការគោលនយោបាយកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងការធ្វើពិពិធកម្ម ក្នុងគោលដៅស្វែងរកជន្ទល់ថ្មីៗ ដែលមានតម្លៃបន្ថែមខ្ពស់ដល់សេដ្ឋកិច្ច ដើម្បីបន្តធានាចីរភាពនៃកំណើនក្នុងរយៈពេលមធ្យម និងវែង។

យោងតាមទិន្នន័យស្ថិតិផ្លូវការដើមឆ្នាំ ២០១៧ របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០១៧ ត្រូវបានប៉ាន់ស្មានថា នឹងរក្សាបានកំណើនក្នុងរង្វង់ ៧,០%។ ក្នុងនោះ វិស័យឧស្សាហកម្មនៅតែមានកំណើនរឹងមាំ ក្នុងអត្រាពីរខ្ទង់ដដែល ពោលគឺប្រមាណ ១០,៧% ដែលនឹងបន្តដើរតួនាទីជាក្បាលម៉ាស៊ីនជំរុញកំណើនសេដ្ឋកិច្ចទីមួយ ដឹកមុខដោយវិស័យកាត់ដេរ និងការរីកធំធាត់នៃវិស័យមិនមែនកាត់ដេរ បើទោះបីជាវិស័យសំណង់មានការថមថយបន្តិចក្តី។ វិស័យកសិកម្មអាចនឹងមានកំណើនល្អ ពោលគឺក្នុងអត្រា ២,០% បើប្រៀបធៀបនឹងឆ្នាំ ២០១៦ ក្នុងអត្រា ១,៨% ដោយសារកត្តាអាកាសធាតុដែលមានស្ថានភាពល្អប្រសើរជាងឆ្នាំមុន និងការងើបឡើងវិញនៃតម្លៃទំនិញ ខណៈដែលវិស័យសេវាកម្មអាចនឹងមានកំណើនយឺតជាងឆ្នាំមុនជាមួយនឹងអត្រាកំណើន ៦,៥% ដោយសារការបន្តថមថយនៃវិស័យទេសចរណ៍ និងអចលនទ្រព្យ។

ជាមួយនឹងកំណើនរឹងមាំក្នុងឆ្នាំ ២០១៧ នេះ ផ.ស.ស ថ្លៃបច្ចុប្បន្នត្រូវបានប៉ាន់ស្មានថា នឹងកើនឡើងដល់ ២២,២ ប៊ីលានដុល្លារអាមេរិក ដែលធ្វើឱ្យ ផ.ស.ស សម្រាប់មនុស្សម្នាក់អាចនឹងកើនឡើងដល់ ១.៤៣៤ ដុល្លារ អាមេរិក។ លើសពីនេះ កម្ពុជាអាចរក្សាបាននូវអតិផរណា ដែលស្ថិតក្នុងកម្រិតទាប និងអាចគ្រប់គ្រងបាន ដោយ អតិផរណាជាមធ្យមប្រចាំឆ្នាំ ត្រូវបានប៉ាន់ស្មានថា នឹងមានអត្រា ៣,៨% ក្នុងឆ្នាំ ២០១៧ កើនពី ៣,០% ក្នុងឆ្នាំ ២០១៦ ដោយសារនិន្នាការកើនឡើងនៃថ្លៃប្រេងក្នុងទីផ្សារអន្តរជាតិ និងតម្លៃម្ហូបអាហារក្នុងស្រុក។ ជាមួយគ្នានេះដែរ អត្រាប្តូរប្រាក់នៅបន្តមានស្ថិរភាពជាមួយនឹងការរំពឹងទុកថា ប្រាក់រៀលនឹងនៅបន្តរក្សាបាននូវតម្លៃប្រមាណ ៤.០៣៧ រៀល ក្នុង ១ ដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០១៧ នេះ។